## ព្រឹត្តិបត្រសង្ខេបទន្លេមេគង្គ លេខ៩ ខែវិច្ឆិកា ឆ្នាំ២០០៨

### តើការសិក្សារបស់ MRC ប្រាប់យើងអំពីភាពជំពាក់ជំពិននៃទំនប់តាមដង ទន្លេមេគង្គចំពោះមច្ឆជាតិយ៉ាងណា?

- តាមការវាយតម្លៃលើមច្ឆជាតិរបស់លេខាធិការមេគង្គឆ្នាំ១៩៩៤ ដែលពាក់ព័ន្ធនឹងទំនប់តាមដងទន្លេមេគង្គក្រោមបានសន្និដ្ឋានថា តម្រូវការចំណេះដឹងគឺត្រូវមានបន្ថែមទៀតដើម្បីធ្វើការវាយតម្លៃទំនប់ដែលអាចជឿជាក់បាន។
- ចាប់តាំងពីឆ្នាំ១៩៩៥ អ្នកផ្តល់ជំនួយបានវិនិយោគមួយចំនួនធំក្នុងកិច្ចការស្រាវជ្រាវដែលធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គ (MRC)។

លទ្ធផលស្រាវជ្រាវរបស់ MRC បញ្ជាក់ថា ៖

- តម្លៃដ៏ច្រើនឥតគណនានៃទិន្នផលត្រីទន្លេមេគង្គ គឺបានរួមចំណែកក្នុងសេដ្ឋកិច្ចនៃប្រទេសទាំងអស់នៅទន្លេមេគង្គក្រោម ក៏ដូចជាអាហារូបត្ថម្ភ ប្រាក់ចំណូល ជីវភាពរស់នៅ និងសុវត្ថិភាពស្បៀង។
- ផលិតភាពនៃមច្ឆជាតិប្រកបដោយស្ថិរភាព និងចីរភាព គឺអាស្រ័យលើសម្ព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធទន្លេមេគង្គ។
- កត្តាគំរាមកំហែងធំៗចំពោះភាពរឹងប៉ឹង និងចីរភាពទៅអនាគតនៃមច្ឆជាតិទន្លេមេគង្គ និងការនេសាទ គឺការអភិវឌ្ឍទាំងឡាយណាដែល ៖
    - រាំងខ្ទប់ដំណើរផ្លាស់ទីរបស់ត្រី
    - រេចរិលដល់ជម្រកជលជាតិ
    - ប៉ះពាល់ដល់ធារទឹកហូរ
- ទំនប់តាមដងទន្លេ នឹងរាំងខ្ទប់ដល់ដំណើរផ្លាស់ទីរបស់ត្រី និងធ្វើឲ្យរេចរិលដល់ជម្រកជលជាតិ។ ទំហំនៃផលប៉ះពាល់ គឺអាស្រ័យលើទំហំ និងដំណើរការនៃទំនប់។
- វិធីកាត់បន្ថយប្រកបដោយប្រសិទ្ធភាពចំពោះឧបសគ្គដែលបង្កដោយទំនប់មកលើការបំលាស់ទីរបស់ត្រីនៅតាមទន្លេមេគង្គ គឺមិនទាន់មានអ្នកចេះដឹងនៅឡើយទេ។

ព្រឹត្តិបត្រនេះ គឺដកស្រង់ព័ត៌មានជាបឋមពីការបោះពុម្ពផ្សាយរបស់គណៈកម្មការទន្លេមេគង្គ (MRC) ដែលបានចងក្រងឯកសារពីភាពចាំបាច់នៃមច្ឆជាតិ និងការនេសាទនៅទន្លេមេគង្គ និងសក្តានុពលភាពនៃការជំពាក់ជំពិនជាមួយទំនប់តាមដងទន្លេលើការនេសាទ សេដ្ឋកិច្ច និងជីវភាពរស់នៅ។

## សាវតារ

ក្នុងឆ្នាំ១៩៩៤ ពោលគឺពីរបីខែមុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ លេខាធិការទន្លេមេគង្គ បានបោះពុម្ពផ្សាយពីការសិក្សាមួយ ដែលបានកំណត់ និងចង្អុលបង្ហាញពីទីតាំង១១កន្លែងដែលមានសក្តានុពលក្នុងការសាងសង់ទំនប់វារីអគ្គីសនីនៅតាមដងទន្លេមេគង្គក្រោម។ ក្នុងចំណោមកន្លែងទាំងនេះ ការសិក្សានេះ បានកំណត់អាទិភាពទំនប់តាមដងទន្លេដែលប្រើ "ចរន្តទឹកហូរធម្មជាតិ" ៩កន្លែងបន្ថែមទៀតសម្រាប់ការសិក្សាពេលក្រោយ ដែលអាចផលិតថាមពល ១៣.៣៥០ មេហ្គាវ៉ាត់ [1]។ ទំនប់ទាំងនេះ ជាជម្រើសមួយផ្សេងទៀតជំនួសឲ្យល្បាក់ទឹកនៃទំនប់ធំៗដែលមានក្នុងផែនការចង្អុលបង្ហាញដោយគណៈកម្មការទន្លេមេគង្គរវាងឆ្នាំ១៩៧០ និង១៩៨៧។

លេខាធិការទន្លេមេគង្គក៏ត្រូវបានអនុញ្ញាតឲ្យធ្វើកិច្ចការវាយតម្លៃលើផលប៉ះពាល់ដែលអាចកើតឡើងមកពីទំនប់តាមដងទន្លេលើមច្ឆជាតិ និងការនេសាទ[2]។ ការវាយតម្លៃលើការនេសាទ បានពន្លេច (ក្នុងចំណោមបញ្ហាផ្សេងៗ) ពីភាពខ្វះខាតព័ត៌មានលម្អិតស្តីពីអេកូឡូស៊ីនៃមច្ឆជាតិ - ស្តុកត្រី លំនាំបំលាស់ទី ទីតាំង និងលក្ខណៈនៃជម្រកពងកូន និងការចិញ្ចឹមជីវិតរបស់មច្ឆជាតិ - ចំពោះកន្លែងប្រសព្វនៃដៃទន្លេទាំងអស់នៅអាងទន្លេមេគង្គក្រោម (LMB) ហើយបានសន្និដ្ឋានថា "គម្រោងទាំងនេះ គឺមិនរៀបគម្រោងប្លង់ប្រកបដោយសុវត្ថិភាព ឬមិនអាចកាត់បន្ថយបញ្ហាទេ ប្រសិនបើគ្មានការបង្កើតឲ្យមានទិន្នន័យដែលសមស្រប និងទុកចិត្តបាន" [2:92]។

ដូច្នេះ ការវាយតម្លៃមច្ឆជាតិ បានផ្តល់អនុសាសន៍ឲ្យមានការសិក្សាក្នុងពេលឆាប់ៗ និងពេលយូរមួយចំនួនដើម្បីវាយតម្លៃ "ផលប៉ះពាល់ពីគម្រោងជាក់លាក់ទាំងឡាយ ការកាត់បន្ថយផលប៉ះពាល់ ផលប៉ះពាល់ដែលកើតឡើងជាលក្ខណៈត្រួតគ្នា ឬបន្សំគ្នា និងទីតាំងគម្រោងសម្រាប់ជំនួស និងវិសាលភាពផលប៉ះពាល់" ក៏ដូចជា "ការសិក្សាលម្អិតពីអេកូឡូស៊ីមច្ឆជាតិនៅទំនាបលិចទឹក និងដងទន្លេ ដោយរាប់បញ្ចូលទាំងទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច" [2:92] ។ អនុសាសន៍នេះ ជាការលើកឡើងម្តងទៀតនូវអ្វី ដែលធ្លាប់បានផ្តល់ក្នុងអត្ថបទ **ពិនិត្យវាយតម្លៃលើផ្នែកមច្ឆជាតិឆ្នាំ១៩៩២** ក្នុង LMB បោះពុម្ពផ្សាយដោយគណៈកម្មការទន្លេមេគង្គបណ្តោះអាសន្ន ដែលពោលថា "ការអភិវឌ្ឍទំនប់តាមដងទន្លេមិនគួរធ្វើឡើងដោយគ្មានការវាយតម្លៃលម្អិតបែបនេះទេ[3:xii]។

ក្រោយមក១៤ឆ្នាំ ចំណាប់អារម្មណ៍ជាថ្មីក្នុងការធ្វើទំនប់តាមដងទន្លេមេគង្គ បានលើកឡើងនូវសំណួរអំពីសក្តានុពលភាពនៃផលប៉ះពាល់លើមច្ឆជាតិ និងជីវភាពរស់នៅរបស់ប្រជាជននៅតំបន់អាងទន្លេ។ ដូច Jeremy Bird (នាយកប្រតិបត្តិនៃលេខាធិការ MRC បានលើកឡើងថា "គួរឲ្យសោកស្តាយណាស់ ការសិក្សាសំខាន់ៗដើម្បីបំពេញព័ត៌មានខ្វះខាតនេះ មិនត្រូវបានធ្វើឡើង។ ឥឡូវនេះ យើងត្រូវធ្វើដំណើរទៅមុខឲ្យបានលឿន ដើម្បីសងវិញនូវពេលវេលាដែលបាត់បង់។ បញ្ហាប្រឈម គឺពិនិត្យមើលថាតើ អ្វីអាចធ្វើបានជាមួយនឹងចំណេះដឹងដែលមាន ដើម្បីទទួលយកនូវទស្សនៈបញ្ចូលគ្នាបន្ថែមទៀត[4]។

## MRC - បង្កើតចំណេះដឹងពីការនេសាទ

តាំងពីកំណើតនៅឆ្នាំ១៩៩៥ ថវិការាប់លានដុល្លាត្រូវបានបញ្ជូនឲ្យកម្មវិធីមច្ឆជាតិរបស់ MRC ដើម្បីបង្កើតចំណេះដឹងពីមច្ឆជាតិ និងការនេសាទនៅទន្លេមេគង្គ។ បើទោះជាគ្មានដំណោះស្រាយជាក់លាក់ណាមួយស្តីពីផលប៉ះពាល់ដោយសារទំនប់តាមដងទន្លេ កម្មវិធីមច្ឆជាតិ បានផលិតនូវព័ត៌មានសំបូរបែប នៅតាមទន្លេមេគង្គ ដែលទាក់ទងនឹងទំហំ និងគុណតម្លៃនៃការនេសាទ សេដ្ឋកិច្ច សារៈសំខាន់នៃជីវភាពរស់នៅ ដំណើរការអេកូឡូស៊ី និងលក្ខណៈសម្បត្តិនៃតួនាទីដែលគាំទ្រដល់មច្ឆជាតិ រួមមាន តួនាទីសម្រាប់ការបំលាស់ទីរបស់ត្រី និងការគំរាមកំហែលសំខាន់ៗចំពោះផលិតភាពជាបន្តបន្ទាប់ និងចីរភាពនៃមច្ឆជាតិនៅទន្លេមេគង្គ។

## ទំហំ និងគុណតម្លៃនៃមច្ឆជាតនៅទន្លេមេគង្គ

*ជីវចម្រុះនៃជលជាតិ*

ទោះបីការប៉ាន់ស្មានចំពោះជីវចម្រុះនៃត្រីទឹកសាប ទន្លេមេគង្គ ខុសគ្នាទៅតាមប្រភពផ្សេងៗ គឺវាអាចមាន ប្រហែលពី៧៨៥ ទៅ១.៥០០ប្រភេទ ចំនួននេះគឺត្រូវ បានទទួលស្គាល់ថា ទន្លេមេគង្គជាកន្លែងស្នាក់នៅនៃ ពពួកសត្វទឹកច្រើនប្រភេទបំផុតលើពិភពលោក ហើយ មានអត្រាប្រភេទសត្វក្នុងស្រុកច្រើនបំផុត [5:12]។ កម្រិត ខ្ពស់នៃនានាភាពត្រី និងប្រភេទជលជាតិ គឺពាក់ព័ន្ធ យ៉ាងស្អិតរមួតទៅនឹងស្ថានប្រព័ន្ធដែលស៊ាំញ៉ាំរបស់ទន្លេ មេគង្គ និងជាកត្តាចម្បងក្នុងការចូលរួមឲ្យមានផលិតភាព និង ទិន្នផលនេសាទខ្ពស់ជាងគេ [6]។

*ការប៉ាន់ស្មានពីផលិតភាព និងទិន្នផលត្រី*

ការទទួលស្គាល់កាន់តែច្រើនឡើងនៃសារៈសំខាន់ របស់មច្ឆជាតិ និងការនេសាទនៅទន្លេមេគង្គ គឺឆ្លុះបញ្ចាំង តាមរយៈទិន្នផលចាប់សរុប (ដែលមានបរិមាណកើន ឡើងគួរឲ្យកត់សម្គាល់ តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០) ដែលមានក្នុងរបាយការណ៍ប៉ាន់ស្មានប្រចាំឆ្នាំសម្រាប់ជា ភស្តុតាង និងការស្រាវជ្រាវនៃកម្មវិធីនេសាទរបស់ MRC កាលពីឆ្នាំកន្លងមក (មើលតារាងលេខ ១)។

ការប៉ាន់ស្មានដែលទើបនឹងបោះពុម្ពពេលថ្មីៗនេះ បង្ហាញពីទិន្នផលចាប់ច្រើនជាង៣លានតោនក្នុងមួយឆ្នាំ ក្នុងចំណោមនេះ ៨០ភាគរយបានមកពីការនេសាទក្នុង ទន្លេ។ ទិន្នផលនេះ ធ្វើឲ្យអ្នកជំនាញអះអាងថា ទន្លេមេគង្គ ជាកន្លែងនេសាទត្រីទឹកសាបធំជាងគេលើពិភពលោក [7,8] ដែលចំនួននេះគឺមានប្រហែល២ភាគរយនៃទិន្នផល នេសាទទឹកសាប និងទឹកប្រៃសរុបលើពិភពលោក[9]។

| ឆ្នាំ | ទិន្នផលចាប់/តោន |
|---|---|
| ១៩៩១ | ប្រហែល ៣៥៦.០០០ |
| ២០០០ | > ១លាន |
| ២០០២ | > ២លាន (១,៥៣លានតោន ត្រីចាប់បានពីទន្លេ) |
| ២០០៥ | > ៣លាន (២,៦៤លានតោន ត្រីចាប់បានពីទន្លេ) |

**តារាងលេខ ១ ៖** ការប៉ាន់នៃទិន្នផលត្រីក្នុង LMB
**ប្រភព ៖** MRC Fisheries Programme Annual Reports 2001:4; 2002:4; 2005:4-5.

*តម្លៃសេដ្ឋកិច្ច*

ការនេសាទនៅទន្លេមេគង្គ មានតម្លៃប៉ាន់ស្មានថា ប្រហែលជា២០០០-៣០០០លានដុល្លាសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំៗ [8, 10]។ តម្លៃនេះបានចូលរួមយ៉ាងសំខាន់ ក្នុងសេដ្ឋកិច្ចនៃប្រទេសមេគង្គក្រោម។ យ៉ាងនេះក្តី MRC ធ្វើការកត់សម្គាល់ថា ការប៉ាន់ស្មាននេះ គឺ "ប៉ាន់ស្មើរ ចំពោះទំហំម៉ាក្រូសេដ្ឋកិច្ចនៃវិស័យជលផល ព្រោះការ ប៉ាន់ស្មាននេះ គឺមិនរាប់បញ្ចូលតម្លៃបន្ថែមបានពីការ លក់បន្ត ការនាំចេញ ឬឧស្សាហកម្មដែលពាក់ព័ន្ធ [10:4]។ ដូច្នេះ "ការអនុញ្ញាតឲ្យមានឥទ្ធិពលជាពហុគុណ លើវិស័យនេសាទ គឺបង្កើនតម្លៃច្រើនបន្ថែមទៀត ដែល ក្នុងនោះគឺមានតួលេខ និងតម្លៃបន្ថែមខ្ពស់ណាស់ [11:4]។ លើសពីនេះទៀត ការប៉ាន់ស្មានទិន្នផលនេសាទ និង ការចូលរួមចំណែកក្នុងសេដ្ឋកិច្ចជាតិ គឺមិនបានបង្ហាញ ឲ្យអស់ពីតម្លៃមច្ឆជាតិ ពោលគឺវាពាក់ព័ន្ធនឹងប្រាក់ចំណូល របស់គេហព័ន្ធ អាហារូបត្ថម្ភ ជីវភាពរស់នៅ និងវប្បធម៌ របស់ប្រជាជនទេ។

*គុណតម្លៃនៃជីវភាពរស់នៅ និងអាហារូបត្ថម្ភ*

លទ្ធផលស្រាវជ្រាវរបស់ MRC ពោលថា "ទិន្ន ន័យផ្លូវការទាំងអស់ស្តីពីទិន្នផលនេសាទ គឺមានចំនួន តិចជាងការប៉ាន់ស្មានដែលបានមកពីទិន្នន័យបរិភោគ។ ទិន្នន័យជាតិ មិនបានរាប់បញ្ចូល ឬរាយការណ៍មិនអស់ អំពីផលនេសាទដែលបានមកពីអ្នកនេសាទតូចតាច និង អ្នកនេសាទគ្រួសារ ប៉ុន្តែបរិមាណចាប់របស់អ្នកទាំងនោះ គឺចូលរួមមួយភាគធំក្នុងទិន្នផលចាប់សរុប [12:74]។ ក្នុង របាយការណ៍ស្តីពីស្ថានភាពអាងឆ្នាំ២០០៣ MRC ក៏ធ្វើ ការកត់សម្គាល់ផងដែរថា "វាមានភាពកាន់តែច្បាស់លាស់ ថា ប្រជាជនក្នុងតំបន់ គឺពឹងអាស្រ័យយ៉ាងខ្លាំង ពោលគឺ ខ្លាំងជាងកម្រិតដែលគេយល់ឃើញពីមុនមក ចំពោះការ នេសាទពីដងទន្លេមេគង្គសម្រាប់អាហារូបត្ថម្ភ ប្រាក់ ចំណូល និងជីវភាពរស់នៅរបស់គេហព័ន្ធ [13:106]។

លទ្ធផលនៃការអង្កេត បានបង្ហាញថា រវាង៦៤ ទៅ ៩៣ភាគរយនៃគេហព័ន្ធតាមជនបទនៅអាងទន្លេមេគង្គ ក្រោម គឺមានពាក់ព័ន្ធនឹងការនេសាទ ដោយមានការ ចាប់ត្រីក្នុងទន្លេ ជាផ្នែកមួយដ៏ធំក្នុងការផ្តល់ឲ្យគេហព័ន្ធ នូវអាហារូបត្ថម្ភ និងប្រាក់ចំណូល [6:14] ។ ការបរិភោគ ត្រី និងជលជាតិផ្សេងៗទៀត បានផ្តល់នូវប្រូតេអ៊ីន

ប្រហែល៤៧ ទៅ៨០ភាគរយ (អាស្រ័យទៅតាមប្រទេស [12]) និងប្រភពដ៏ចម្បងនៃ "សារធាតុសំខាន់ៗ (រួមមាន កាល់ស្យូម ដែក និងស័ង្កសី) និងវីតាមីន - ជាពិសេស វីតាមីន អា" [12:2]។

ខណៈដែលមានការពិបាក ក្នុងការកំណត់គុណតម្លៃនៃអាហារូបត្ថម្ភពីត្រី និងជលជាតិ មានតម្លៃសេដ្ឋកិច្ចយ៉ាងសំខាន់ ព្រោះថា "វិបាកនៃសេដ្ឋកិច្ចដោយសារកង្វះខាត គឺនាំមកនូវវដ្តកង្វះអាហារូបត្ថម្ភ ផលិតភាពទាប និងភាពក្រីក្រ" [5:12]។ អាហារដែលអាចមកជំនួសម្ហូបត្រីសម្រាប់ប្រជាជនក្នុងអាងទន្លេមេគង្គ គឺមិនទាន់មាននៅឡើយ[11] ។ លើសពីនេះទៀត ទោះមានវិនិយោគលើវារីវប្បកម្មខ្នាតធំក្តី មានការប៉ាន់ស្មានថា ៩០ភាគរយនៃបរិមាណបរិភោគគឺបានពីការនេសាទនៅទន្លេ នេះគឺបញ្ជាក់ថា វារីវប្បកម្ម គឺមិនអាចជំនួសឲ្យត្រីក្នុងទន្លេទាំងមូលបានទេ [12:74]។

## មច្ឆជាតិ - ដំណើរការអេកូឡូស៊ី លក្ខណៈនៃមុខងារ

### *ការបំលាស់ទីរបស់ត្រី*

ការបំលាស់ទីរបស់ត្រី ដើរតួយ៉ាងសំខាន់ក្នុងមុខងារ និងផលិតភាពនៃស្ថានប្រព័ន្ធទន្លេមេគង្គ។ ៨៧ភាគរយនៃប្រភេទត្រីទន្លេមេគង្គ ជាប្រភេទត្រីដែលបំលាស់ទី នេះបើតាមព័ត៌មានដែលមាន[14]។ ប្រភេទត្រីជាច្រើន ធ្វើដំណើរយ៉ាងឆ្ងាយ ឆ្លងកាត់ព្រំដែនពីប្រទេសមួយទៅប្រទេសមួយ ដើម្បីរកចំណី ជម្រករបស់ត្រីបំលាស់ទី និងកន្លែងពងកូនក្នុងពេលខុសគ្នា និងដំណាក់កាលខុសៗគ្នានៃវដ្តជីវិតរបស់ត្រីទាំងនោះ។ ការពឹងផ្អែករបស់ត្រីលើទីជម្រកតាមរដូវដែលស្ថិតនៅភូមិសាស្ត្រផ្សេងៗ ត្រូវបានចាត់ចូលថា ជាកត្តាជំរុញពាក់ព័ន្ធនឹងការបំលាស់ទីរបស់ត្រី ហើយការបំលាស់ទី វាពាក់ព័ន្ធជាមួយនឹងធារទឹកហូររបស់ទន្លេមេគង្គ [15, 16, 17]។

- ***ទំនាបលិចទឹកតាមរដូវ*** ត្រូវបានចាត់ទុកថាជា "កន្លែងបន្តពូជត្រី"ដ៏ចម្បង [17]។ ដូចមានលើកឡើងក្នុងរបាយការណ៍បច្ចេកទេស MRC ឆ្នាំ២០០២មួយថា "ប្រសិនបើគ្មានទឹកជំនន់ និងទំនាបលិចទឹក បរិមាណត្រីចាប់ គឺមានតែមួយភាគតូចនៃចំនួនបច្ចុប្បន្ន [16: 62] ។ ភាពសម្បូរបែបនៃជីជាតិ អាហារ និងជម្រកនៃទំនាបលិចទឹក គឺផ្តល់នូវជម្រកដែលមានអាហារ និងកន្លែងចិញ្ចឹមកូនយ៉ាងសំខាន់បំផុតសម្រាប់ប្រភេទត្រីជាច្រើន [17]។ ជម្រកនៅទំនាបលិចទឹកដ៏សំខាន់នេះ គឺមានចាប់ពីភាគខាងត្បូងនៃប្រទេសកម្ពុជារហូតដល់ដីសណ្តទន្លេមេគង្គនៅប្រទេសវៀតណាម ហើយក្នុងចំណោមនោះ ទន្លេសាប និងវាលទំនាបនៅជុំវិញទន្លេនេះ គឺមានសារៈសំខាន់ណាស់។ នៅពេលទឹកស្រក ត្រីចាកចេញពីទំនាបលិចទឹក ហើយស្វែងរកទីជម្រកនៅតាមកន្លែងដែលមានទឹកជ្រៅតាមដងទន្លេ និងដៃទន្លេ[15]។
- **អាងដងទន្លេជ្រៅ** ផ្តល់នូវជម្រកនៅរដូវក្តៅដ៏សំខាន់សម្រាប់ប្រភេទត្រីបំលាស់ទីសំខាន់ៗជាច្រើន។ តាមបណ្តោយទន្លេពីខេត្តក្រចេះ ទៅល្បាក់ខោន ត្រូវបានកំណត់ថា ជាអាងទន្លេជ្រៅដែលមានសារៈសំខាន់បំផុត។ តាមបណ្តោយអាងនេះ ត្រូវបានចាត់ទុកថាជាកន្លែងផ្តល់នូវជម្រកពងកូនដ៏សំខាន់។

### *ធារទឹកហូរ វដ្តជីវិតត្រី និងទីជម្រក*

មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងធារទឹកហូរទន្លេមេគង្គ វដ្តជីវិត និងការបំលាស់ទីពីជម្រកមួយទៅជម្រកមួយទៀតរបស់ត្រី ដូចមានភស្តុតាងដែលបានបង្ហាញទំនាក់ទំនងយ៉ាងខ្លាំងរវាងប្រភេទត្រីដ៏ច្រើនដែលផ្លាស់ទី និងវដ្តទឹកឡើងចុះទន្លេមេគង្គប្រចាំឆ្នាំ។ ទំហំ និងវិសាលភាពនៃទឹកជំនន់ គឺមានឥទ្ធិពលយ៉ាងខ្លាំងលើផលិតភាពរបស់ត្រី។ ជាទូទៅ ទន្និផលត្រី គឺច្រើនពេលដែល "មានទឹកជន់ខ្លាំង ហើយមានរយៈពេលវែង និងកើតឡើងពេលដែលត្រីត្រូវពងកូន" [18:8]។

បម្រែបម្រួលនៃកម្រិតទឹក (និងការបង្ហូរទឹកចេញ) ជា "កត្តាជំរុញ" នៃការបំលាស់ទីរបស់ត្រី។ នេះជាអ្វីដែលត្រូវបានលើកឡើងជាញឹកញាប់ក្នុងបណ្ណាល័យសាស្ត្រ។ ការពិនិត្យវាយតម្លៃលើកត្តាជំរុញនៃការបំលាស់ទីរបស់ត្រី ដែលបោះពុម្ពផ្សាយដោយ MRC បានកត់សម្គាល់ថា "មានចំណេះដឹងតិចតួចណាស់ស្តីពីកត្តាសរីរសាស្ត្រ និងបរិស្ថានដែលនាំមកនូវកត្តាជំរុញដល់ការបំលាស់ទី"។ ក្នុងចំណោមប្រភេទត្រីដែលបំលាស់ទីគេបានដឹងរួចមកហើយថា "មាន៩០ភាគរយ គឺឆ្លើយតបនឹងបម្រែបម្រួលនៃកម្រិតទឹក ឬការបង្ហូរទឹកចេញ [14:ix]។

*ការនេសាទគឺអាស្រ័យលើស្តុកត្រីបំលាស់ទី*

ចាប់ពីអ្នកនេសាទត្រីសម្រាប់តែចិញ្ចឹមជីវិតរហូតដល់អ្នកចាប់ត្រីជាលក្ខណៈពាណិជ្ជកម្មខ្នាតធំ ការនេសាទត្រីនៅទន្លេមេគង្គ គឺពឹងផ្អែកលើ និងបានតម្រូវតាមស្តុកត្រីបំលាស់ទីសម្រាប់នេសាទ។ ឧទាហរណ៍ នៅកម្ពុជា ស្តុកត្រីបំលាស់ទីចូលរួមមួយភាគធំនៃបរិមាណចាប់ប្រចាំឆ្នាំ ពោលគឺប្រហែលជា៨០០.០០០តោនក្នុងមួយឆ្នាំ[19] ។ ស្រដៀងគ្នានេះដែរ ភាគច្រើននៃបរិមាណនេសាទប្រចាំឆ្នាំនៅល្បាក់ខោន (កន្លែងមួយក្នុងចំណោមសម្បុកត្រីសំខាន់នៅប្រទេសឡាវ) គឺមានស្តុកត្រីដែលផ្លាស់ទី[14]។ តាមការប៉ាន់ស្មាន ក្នុងចំណោមបរិមាណចាប់ក្នុងអាងទាំងអស់ គឺមានច្រើនជាង៧០ភាគរយជាត្រីដែលបំលាស់ទីក្នុងចម្ងាយឆ្ងាយនៅអាងទន្លេមេគង្គក្រោម[8]។

ភ្ជាប់ជាមួយភាពចាំបាច់នៃការបំលាស់ទីរបស់វដ្តជីវិតត្រី កម្មវិធីមច្ឆជាតិរបស់ MRC បានសំណូមពរឲ្យមាន "វិធីសាស្ត្រស្ថានប្រព័ន្ធ" សម្រាប់ការគ្រប់គ្រងមច្ឆជាតិនៅ LMB។ វិធីសាស្ត្រនេះ គឺផ្តោតលើការការពារការរួមបញ្ចូលគ្នានៃប្រព័ន្ធទន្លេ ការរក្សាឲ្យបាននូវទំនាក់ទំនងគ្នារវាងទីជម្រកសំខាន់ៗ (មានន័យថារបៀងបំលាស់ទី) និងការពន្លេចពីភាពចាំបាច់នៃលំនាំជលធារសាស្ត្រប្រចាំឆ្នាំ ដោយរាប់បញ្ចូលទាំងតួនាទីក្នុងការបង្កើតឡើងនៃទីជម្រកនៅតំបន់ទំនាប់លិចទឹកតាមរដូវ [15, 16, 20]។

បច្ចុប្បន្ននេះ ការទទួលស្គាល់មានការកើនឡើងថា ទោះបីមានការនេសាទត្រីមិនរក្សាបាននូវចីរភាពដែលដាក់សម្ពាធមកលើធនធាននេសាទក្តី តែការគំរាមកំហែងជាចម្បងចំពោះចីរភាពនៃធនធាននេសាទនៅទន្លេមេគង្គនោះគឺ កើតពីការអភិវឌ្ឍក្នុងអាងដែលប៉ះពាល់ដល់ភាពរួមបញ្ចូលគ្នានៃអេកូឡូស៊ីរបស់ប្រព័ន្ធទន្លេមេគង្គ [15, 16, 20]។

## ការគំរាមកំហែងចំពោះមច្ឆជាតិទន្លេមេគង្គ

បច្ចុប្បន្ននេះ គឺមានការឯកភាពយ៉ាងទូលំទូលាយថា ការគំរាមកំហែងជាចម្បងចំពោះមច្ឆជាតិនៅទន្លេមេគង្គ គឺពាក់ព័ន្ធនឹងសកម្មភាពដែលផ្លាស់ប្តូរធារទឹកហូរធម្មជាតិ ធ្វើឲ្យខូចខាត ឬបំផ្លាញជម្រកត្រី និង/ឬរាំងខ្ទប់ ឬធ្វើឲ្យទើសទែងដល់ដំណើរបំលាស់ទីរបស់ត្រី [15, 16, 18, 20]។ "ទំនប់ និងគម្រោងគ្រប់គ្រងទឹកជំនន់ ជាពិសេសគឺកាត់បន្ថយមច្ឆជាតិនៅទីទំនាបលិចទឹករបស់ទន្លេ ព្រោះថាទំនប់ និងគម្រោងទាំងនោះបង្កផលប៉ះពាល់ទាំងនេះ" [18:30]។ ការគំរាមកំហែងពីទំនប់បង្កឡើងលើចីរភាពនៃមច្ឆជាតិនៅទន្លេមេគង្គនាពេលអនាគតនោះ គឺត្រូវបានទទួលស្គាល់ដោយ MRC និងស្ថាប័នផ្សេងទៀត ៖

- ឯកសារបច្ចេកទេសរបស់ MRC ឆ្នាំ២០០៤ មួយ បានកំណត់ពី ផលប៉ះពាល់នៃហេដ្ឋារចនាសម្ព័ន្ធជលធារថាជា "ការគំរាមកំហែងទីមួយ និងចម្បងគេចំពោះមច្ឆជាតិ និងការនេសាទនៅទន្លេមេគង្គ [20:19]។
- របាយការណ៍ឆ្នាំ២០០៧មួយបោះពុម្ពដោយគណៈកម្មការមេគង្គជាតិកម្ពុជា (CNMC) និង មជ្ឈមណ្ឌលត្រីពិភពលោក (WorldFish Center (WFC)) ពោលអះអាងថា "ទំនប់ ជារចនាសម្ព័ន្ធចម្បងដែលមានផលប៉ះពាល់លើផលិតផលនេសាទ ដោយសារផលប៉ះពាល់ជាអវិជ្ជមានលើការបំលាស់ទីរបស់ត្រី [19:24]។
- ក្នុងឯកសារមួយដែលធ្វើបទបង្ហាញនៅសន្និសិទ្ធមច្ឆជាតិអន្តរជាតិមួយធ្វើឡើងនៅសាកលវិទ្យាល័យ Ubon Ratchathani ក្នុងខែកញ្ញា ឆ្នាំ២០០៨នេះ Chris Barlow ដែលជាអ្នកគ្រប់គ្រងកម្មវិធីមច្ឆជាតិរបស់ MRC បានអះអាងថា ទំនប់នៅតាមដងទន្លេមេគង្គ "នឹងជាកត្តាបំផ្លាញខ្លាំងបំផុតចំពោះមច្ឆជាតិជាពិសេសលើប្រភេទត្រីដែលបំលាស់ទី (ប្រភេទត្រីពណ៌ស) ក្នុងទន្លេមេគង្គ [21:19] ។

**ការប៉ះពាល់លើមច្ឆជាតិជាចម្បងនៃទំនប់ដែលមានស្រាប់ទាំងបីនៅ LMB** [អត្ថបទដកស្រង់ពី MRC (2003) *State of the Basin: 2003*, p.112.]

**ទំនប់ណាមស៊ុង (Nam Song) ប្រទេសឡាវ ៖** *"បន្ទាប់ពី បញ្ចប់ការសាងរបាំងណាមស៊ុងនៅឆ្នាំ១៩៩៦ ត្រី៩០ប្រភេទត្រូវបាត់បង់ និងត្រីបំលាស់ទីឆ្លង់កាត់ព្រំដែនប្រទេស២០ប្រភេទទៀត មិនធ្លាប់មានអ្នកចាប់បាននៅក្នុងប្រទេសជិតខាង។ ក្នុងចំណោមនេះដែរ ២០ប្រភេទជាត្រីបំលាស់ទីឆ្លងកាត់ព្រំដែន (TBM) ឬជាប្រភេទត្រីដែលបំលាស់ទីក្នុងចម្ងាយឆ្ងាយ (LDM)។*

**ទំនប់ផាកម៉ុន (Pak Mun) ប្រទេសថៃ ៖** *មុនពេលចាក់ដីបំពេញធ្វើទំនប់ផាកម៉ុន... មានត្រី២៦៥ ប្រភេទ ត្រូវបានកត់ត្រាក្នុងនានាភាពនៅជម្រកជលជាតិ ហើយកន្លែងពងកូនរបស់ត្រីគឺអាចអនុញ្ញាតឲ្យត្រីមកពីដងទន្លេមេគង្គចូលបាន។ ក្រោយពីសង់ទំនប់រួច គេឃើញមានត្រីតែ៩៦ប្រភេទត្រូវបានកត់ត្រា ដែលមាននៅផ្នែកខាងលើនៃទំនប់ ហើយក្នុងចំណោមនោះ ៥១ ប្រភេទគឺកំពុងតែធ្លាក់ចុះពីភាពមានសម្បូរបែប។ ការសាងសង់ទំនប់បានបណ្តាលឲ្យមានភាពវិនាសសាបសូន្យនៃប្រភេទត្រីបំលាស់ទីឆ្លងព្រំដែនក្នុងចម្ងាយឆ្ងាយនៅផ្នែកខាងលើនៃទំនប់ ដែលត្រីទាំងនោះ ពីមុនវាមកពងកូននៅតំបន់ទឹកជូរទាំងនេះរាល់ឆ្នាំ"។*

**ទំនប់ ធឿន ហ៊ីនប៊ូន (Theun-Hinboun ប្រទេសឡាវ** *"ប្រភេទត្រីទន្លេមេគង្គជាច្រើននៃក្រុម Cyprinidae និង Gyrinocheilidae គឺស៊ី periphyton (រាវិជាតិដែលភ្ជាប់ទៅនឹង)... ការកើនឡើងនូវកម្រិតទឹកដែលបណ្តាលមកពីគម្រោងវារីអគ្គីសនីណាម ហ៊ីនប៊ូន និងធឿន ហ៊ីនប៊ូន នៅប្រទេសឡាវបានបំផ្លាញទាំងស្រុងនូវពពួក periphyton ដែលជាចំណីរបស់ប្រភេទត្រីជាច្រើន"។*

## តើនេះមានន័យយ៉ាងណាចំពោះទំនប់តាមដងទន្លេ?

*លទ្ធផលរកឃើញជាច្រើនបានពីការវាយតម្លៃមច្ឆជាតិរបស់លេខាធិការទន្លេមេគង្គឆ្នាំ១៩៩៤ចំពោះទំនប់តាមដងទន្លេ*

ការវាយតម្លៃលើមច្ឆជាតិឆ្នាំ១៩៩៤ ដែលបោះពុម្ពដោយលេខាធិការទន្លេមេគង្គ គឺជាការសិក្សាមួយដែលអាចឲ្យសាធារណៈជនមើល ហើយបានវាយតម្លៃយ៉ាងពិសេសចំពោះសក្តានុពលភាពនៃផលប៉ះពាល់ដោយសារទំនប់តាមដងទន្លេមេគង្គក្រោម។ ខណៈដែលការសិក្សាពន្លេចពីកង្វះខាននៃទិន្នន័យមូលដ្ឋានលើមច្ឆជាតិជាឧបសគ្គមួយដ៏ចម្បងដើម្បីធ្វើការវាយតម្លៃឲ្យបានសមស្រប ចំពោះផលប៉ះពាល់ដោយសារទំនប់តាមដងទន្លេ ការសិក្សានេះបានលើកឡើងពីចំណុចកង្វល់ជាច្រើនស្មើជាសំណើថា ទំនប់ប្រើ "ចរន្តទឹកហូរធម្មជាតិ" គឺនាំមកនូវហានិភ័យយ៉ាងខ្លាំងចំពោះភាពរឹងប៉ឹង និងចីរភាពនៃមច្ឆជាតិតាមទន្លេមេគង្គ ៖

- ដោយមានគម្រោង៦ដែលស្នើឡើងចំពោះតំបន់ភាគខាងជើងប្រទេសឡាវ និងព្រំដែនឡាវ-ថៃ (ពោលគឺ Pak Beng, Luang Prabang, Pak Lay, Xayabouri, Chiang Khan/Xanakham, Pa Mong/Pak Chom) អ្នកនិពន្ធធ្វើការកត់សម្គាល់ថា ប្រសិនបើទំនប់ទាំង៦ត្រូវបានសាងរួច "ទំនប់ទាំងនេះនឹងបំបាត់ទាំងអស់នូវចំណុចប្រសព្វនៃខ្សែទឹកដែលធ្លាប់តែហូរដោយសេរី និងបង្វែរជាប្រព័ន្ធល្បាក់ទឹកដែលនឹងជន់លិចតំបន់ពងកូន បំបាត់តំបន់ដីសើម និងជម្រកតាមច្រាំងទន្លេ ពន្យាពេលត្រីញាស់នៅផ្នែកខាងក្រោមទំនប់ រាំងខ្ទប់ការផ្លាស់ទីទៅផ្នែកខាងលើទំនប់ បណ្តាលឲ្យស្លាប់ដោយសារទួរប៊ីន ជន់លិចចំណុចប្រសព្វដៃទន្លេ និងបង្កឲ្យបម្រែបម្រួលប្រភេទត្រី និងកាត់បន្ថយជីវចម្រុះ [2:53]។
- ការសិក្សា ពិពណ៌នាអំពីល្បាក់ខោនថាជា "តំបន់អេកូឡូស៊ីតែមួយគត់ដែលចាំបាច់ចំពោះអតិសុខុមប្រាណនៃទន្លេមេគង្គក្រោមទាំងមូល...។ តំបន់បែបនេះ គឺមានដោយកម្រក្នុងធម្មជាតិ ដែលកិច្ចខិតខំប្រឹងប្រែងទាំងអស់ត្រូវធ្វើឡើងដើម្បីអភិរក្សល្បាក់ខោនទាំងនេះមិនឲ្យមានការអភិវឌ្ឍ[2:90]។
- ទាក់ទងនឹងទំនប់សំបូរនៅកម្ពុជា ការសិក្សានេះបញ្ជាក់ថា "គម្រោងសំបូរ [នឹង] ប៉ះពាល់ការបំលាស់ទី[ត្រី] ទាំងផ្នែកខាងលើនិងខាងក្រោមទំនប់។ ប្រភេទត្រីមួយចំនួននឹងមិនអាចទៅដល់កន្លែងពងកូនដែលនៅចន្លោះពីសំបូរ និងស្ទឹងត្រែងទេ។ មិនត្រឹមតែការបំលាស់ទីដើម្បីពងកូនដែលត្រូវបានបាត់បង់ទេ តែកម្រិតទឹកនៅខាងមុខទំនប់នឹងប៉ះពាល់ដល់កូនត្រីដែលបំលាស់ទីចូលក្នុងរដូវវស្សា និងចេញក្នុងរដូវ

ប្រាំងទៅកាន់ជម្រកនៅទំនាបលិចទឹក...។ ស្តុកត្រីដែលរងផលប៉ះពាល់ពីទំនប់ (ត្រូវបានកាត់ផ្តាច់ពីកន្លែងពងកូន និងចិញ្ចឹមជីវិត) គឺស្តុកត្រីនៅផ្នែកខាងលើនៃទំនប់ ក្នុងនោះ អាចជាស្តុកត្រីនៅតំបន់ប៉ាក់សេ និងឆ្ងាយពីនេះទៀតក៏ថាបាន និងតំបន់ទន្លេសាបផងដែរ [2:79-80]។

- មានការកត់សម្គាល់ថា គម្រោងទំនប់សំបូរ នឹងមានទីតាំងនៅត្រង់ច្រករបៀង និងវាលទំនាបលិចទឹកដែលជាកន្លែងចិញ្ចឹមជីវិត និងបំលាស់ទីនៃប្រភេទត្រីច្រើនបំផុត" ការសិក្សាពោលថា គម្រោង"នឹងតម្រូវឲ្យមានប្រព័ន្ធជ្រលងប្រកបដោយប្រសិទ្ធភាពសម្រាប់ឲ្យប្រភេទត្រីបំលាស់ទីឆ្លងកាត់ដើម្បីចៀសវាង ឬកាត់បន្ថយជាអតិប្បរមានូវផលប៉ះពាល់។ ជ្រលងត្រីដែលប្រកបដោយប្រសិទ្ធភាពនោះ គឺហាក់ដូចមិនអាចធ្វើទៅបានទេ ដោយសារទាមទារឲ្យមានការស្រាវជ្រាវជាច្រើន ហើយការអភិវឌ្ឍនេះគឺហាក់ដូចជាមិនមានផ្លែផ្កាទៀតផង [2:vi]។
- ការសិក្សាពន្លេចពីសក្តានុពលភាពនៃវិបាករបស់ឥទ្ធិពលដោយសារទំនប់តាមដងទន្លេ ចំពោះត្រីដែលបំលាស់ទីគឺថា ៖ "ផលប៉ះពាល់តែមួយនេះ អាចបណ្តាលឲ្យការលក់ត្រីជុំនឹងថយចុះនៅទន្លេមេគង្គក្រោមទាំងមូល។ ការរាំងខ្ទប់នៃការបំលាស់ គឺបានកាត់ផ្តាច់នូវទំនាក់ទំនងនៃសង្វាក់ជីវសាស្ត្រនៃប្រភេទត្រីផ្លាស់ទី [2:88-89]។

*ការសិក្សាផ្សេងទៀតបានលើកឡើងពីផលប៉ះពាល់នៃទំនប់តាមដងទន្លេលើមច្ឆជាតិ*

ទោះបី MRC បានសិក្សាវាយតម្លៃសេដ្ឋកិច្ចអំពីផលប៉ះពាល់មកលើមច្ឆជាតិ និងសិក្សាពិនិត្យវាយតម្លៃលើពង្រាងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ចំពោះទំនប់ដូន សំហុង និងបានវាយតម្លៃលើទំនប់តាមដងទន្លេមួយចំនួន (ឧទាហរណ៍ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់ជារួម) [4] ឯកសារទាំងនេះ គឺមិនទាន់បញ្ចេញឲ្យសាធារណៈបានអានទេ។ យ៉ាងណាក៏ដោយ លទ្ធផលស្រាវជ្រាវបោះពុម្ពផ្សាយដោយ MRC និងស្ថាប័នផ្សេងទៀត គឺមានបញ្ជាក់ពីទំនាក់ទំនងនៃទំនប់តាមដងទន្លេមកលើមច្ឆជាតិថា ៖

- ព្រឹត្តិបត្រវិទ្យាសាស្ត្រឆ្នាំ២០០៧មួយបោះពុម្ពផ្សាយដោយ WFC បានពន្លេចពីតួនាទីដ៏សំខាន់នៃស្ទឹងហ្វូសំហុង (កន្លែងដែលស្នើសុំសងទំនប់ ដូន ហុង) ថាជាស្ទឹងសម្រាប់ការបំលាស់ទីរបស់ត្រីនៃអាងទាំងមូល។ ផ្អែកតាមការសិក្សាវិទ្យាសាស្ត្រ ព្រឹត្តិបត្រធ្វើកំណត់សម្គាល់ថា "ការរារាំងដំណើរផ្លាស់ទីរបស់ត្រីនៅល្បាក់ខោន គឺនឹងមានពាក់ព័ន្ធជាមួយនឹងសង្គម អេកូឡូស៊ី និងសេដ្ឋកិច្ចនៅអាងទាំងមូល [7:2]។
- យោងតាមរបាយការណ៍ស្ថានភាពអាងទន្លេឆ្នាំ២០០៣របស់ MRC "ទំនប់តាមដងទន្លេមួយ (ដែលមានទីតាំងខាងលើល្បាក់ខោន.... នឹងរារាំងដំណើរបំលាស់របស់ត្រីសជំទងដែលចេញពីទំនាបលិចទឹក និងកន្លែងពងកូនផ្សេងទៀតនៅផ្នែកខាងជើងប្រទេសកម្ពុជា...។ ក្នុងអំឡុងពេល [បំលាស់ទីត្រីដ៏ច្រើននេះ] គឺយ៉ាងហោចណាស់មានត្រី៥០.០០០ក្បាលក្នុង១នាទីបានហែលឆ្លងកាត់ត្រង់ចំណុចណាមួយក្នុងបឹងទន្លេសាប។ បច្ចុប្បន្នគឺនៅមិនទាន់មានសំណង់ច្រកណាមួយដែលអាចឲ្យត្រីចំនួននេះឆ្លងកាត់បានទេ [13:114]។
- ការពន្លេចភាពចាំបាច់តាមពោះទន្លេជ្រៅ និងកន្លែងទឹកហូរលឿននៅសំបូរ ក្នុងរបាយការណ៍បច្ចេកទេសឆ្នាំ២០០២មួយរបស់ MRC អះអាងថា "[ទំនប់សំបូរ] ផលប៉ះពាល់លើស្តុកត្រីដែលផ្លាស់ទីនឹងមានទំហំធំធេងណាស់ [17:56]។ ហេតុផលដែលនាំមកនូវការអះអាងនេះរួមមាន ៖ ការផ្លាស់ប្តូរជលវិទ្យានៃផ្នែកខាងលើ និងខាងក្រោមទំនប់ ដែលនឹង "ធ្វើឲ្យទីជម្រកត្រីនៅតាមពោះទន្លេជ្រៅនេះ បំពេញដោយល្បាប់ភក់ និងបាត់បង់ពោះទន្លេនេះតែម្តង" ការរាំងខ្ទប់ ឬការខូចខាតយ៉ាងខ្លាំងចំពោះរបៀងបំលាស់ទីរវាងវាលទំនាបលិចទឹក និងជម្រកនៃត្រីផ្លាស់ទី នឹង "បង្អាក់ដំណើរប្រព័ន្ធឌិម្ភា (larva) អាចធ្វើឲ្យត្រីងាប់ដោយផ្ទាល់ និងមិនផ្ទាល់ [17:56]។
- ឯកសារមួយដែលធ្វើបទបង្ហាញនៅសន្និសិទ្ធបច្ចេកទេសស្តីពីមច្ឆជាតិនៅទន្លេមេគង្គកាលពីឆ្នាំ២០០៣ គឺដូចជាចំហាជាង ទាក់ទងនឹងការវិភាគលើទំនប់សំបូរដែលអាចនឹងប៉ះពាល់ដល់មច្ឆជាតិ ដោយពោលថា "ទំនប់ទាំងឡាយណាដែលសង់នៅតាម

ដងទន្លេមេគង្គ ទោះផ្នែកណាមួយក្នុងប្រទេសកម្ពុជា គឺអាចបំផ្លាញដល់មច្ឆជាតិ ប៉ុន្តែកន្លែងនេះ [សំបូរ] ជាកន្លែងដែលប៉ះពាល់ខ្លាំងបំផុតចំពោះមច្ឆជាតិ [22:65]។

- ធនាគារពិភពលោក/ធនាគារអភិវឌ្ឍន៍អាស៊ី ពង្រាងឯកសារសម្រាប់ពិភាក្សា ស្តីពីយុទ្ធសាស្ត្រជំនួយធនធានទឹកទន្លេមេគង្គ (MWRAS) ដែលបានកត់សម្គាល់ថា "ទន្លេមេគង្គនៅកម្ពុជាគឺមានសក្តានុពលធ្វើទំនប់វារីអគ្គិសនីតាមដងទន្លេ ប៉ុន្តែទោះបីជាទំនប់ដើរដោយចរន្តទឹកធម្មជាតិ ក៏អាចនឹងជន់លិចតំបន់យ៉ាងមហាសាល នឹងប៉ះពាល់លើការបំលាស់ទីរបស់ត្រីតាមបណ្តោយដងទន្លេនេះ។ ការអភិវឌ្ឍបែបនេះ នឹងនាំមកនូវហាយនិភ័យលើអេកូឡូស៊ីសង្គម និងសេដ្ឋកិច្ច ដែលអាចខាតបង់ច្រើនជាងប្រយោជន៍បានមកពីការលក់ភ្លើង [23:15]។
- យោងតាមការវិភាគជលសាស្ត្រចំពោះសេណារីយ៉ូអភិវឌ្ឍដែលមានសក្តានុពល ធ្វើឡើងដោយធនាគារពិភពលោក និងជាផ្នែកមួយនៃ MWRAS និយាយថា "ការអភិវឌ្ឍទាំងឡាយណា ដែលរារាំងដល់ការបំលាស់ទីរបស់ត្រីនៅចំណុចប្រសព្វ ឬផ្នែកណាមួយនៃដៃទន្លេ នឹងប៉ះពាល់ជាអវិជ្ជមានមកលើផលិតផលត្រី។ ទំនប់តាមដងទន្លេ ឬទំនប់តូចតាចនៅមេគង្គកណ្តាល និងក្រោមគឺហាក់ដូចជាមិនគោរពតាមតុល្យភាពសេណារីយ៉ូអភិវឌ្ឍដែលមានចែងក្នុងវត្ថុបំណងនៃកិច្ចព្រមព្រៀង [មេគង្គឆ្នាំ១៩៩៥]។ ជាការពិតណាស់ថា ទំនាក់ទំនងវាលទំនាបលិចទឹកជាគន្លឹះនៃផលិតផលត្រី និងសុខភាពរបស់ទន្លេ ហើយចាំបាច់ត្រូវមានការការពារ [24:73]។

## តើផលប៉ះពាល់នៃទំនប់តាមដងទន្លេលើមច្ឆជាតិអាចបន្ធូបន្ថយបានទេ?

ក្រៅពីការប៉ុនប៉ងជាច្រើនដើម្បីបន្ធូបន្ថយការប៉ះពាល់មច្ឆជាតិ របាយការណ៍មួយរបស់ CNMC និង WFC ពោលថា "គឺគ្មានឧទាហរណ៍ពីផលប៉ះពាល់រយៈពេលវែងជាវិជ្ជមានបង្កដោយទំនប់មកលើមច្ឆជាតិទេ ហើយក៏គ្មានវិធានការណ៍បន្ធូបន្ថយឥទ្ធិពលក្នុងអាងទន្លេមេគង្គដែរ" [19:24]។ វិធានការណ៍ដែលលើកឡើងជាទូទៅរួមមានការបង្កើតអាងស្តុកទឹកសម្រាប់ចិញ្ចឹមមច្ឆជាតិ និងសាងសង់ច្រកឲ្យត្រីឆ្លងកាត់ដើម្បីបន្ធូបន្ថយការលំបាករបស់ត្រីក្នុងការឆ្លងកាត់ទំនប់។ ការសិក្សារបស់ CNMC និង WFC ឆ្នាំ២០០៧អះអាងថា "ត្រីរាប់រយប្រភេទក្នុងចំណោមប្រភេទត្រីក្នុងអាងទន្លេមេគង្គ គឺមានតែត្រី៩ប្រភេទប៉ុណ្ណោះដែលត្រូវបានចិញ្ចឹមក្នុងអាងស្តុកទឹក" ហើយអាងស្តុកទឹកសម្រាប់មច្ឆជាតិ "តែងតែមិនអាចទូទាត់ជាមួយនឹងការបាត់បង់មច្ឆជាតិនៅខ្សែទឹកខាងក្រោមទេ។ លើសពីនេះទៀត "គ្មានឧទាហរណ៍ណាមួយស្តីពីច្រកឆ្លងកាត់ត្រីដែលអាចអនុវត្តបានក្នុងអាងទន្លេមេគង្គទេ" [19:24]។

ស្រដៀងគ្នានេះដែរ ឯកសារបច្ចេកទេសរបស់ MRC ឆ្នាំ២០០២ មួយបានអះអាងថា "គ្មានបច្ចេកវិទ្យាដែលមានស្រាប់ណាមួយដែលអាចជំនះឧបសគ្គដោយសារទំនប់ ឬរបាំងទឹកលើដងទន្លេមេគង្គ ឬលើចំណុចប្រសព្វខាងក្រោមនៃដៃទន្លេធំៗរបស់ទន្លេមេគង្គទេ។ តាមដងទន្លេ ជម្រើសដែលត្រូវជ្រើសគឺថា ការពារត្រី ឬសងទំនប់" [16:86]។

ក្នុងអំឡុងពេលប្រឹក្សាយោបល់នៃកម្មវិធីវារីអគ្គីសនីរបស់ MRC ក្នុងខែកញ្ញា ឆ្នាំ២០០៨ មានបទបង្ហាញមួយ (ធ្វើឡើងជំនួសមុខឲ្យកិច្ចការក្រុមជំនាញឯករាជ្យដែលក្នុងការប្រជុំនោះ គឺធ្វើឡើងដើម្បីពិនិត្យលើឧបសគ្គបង្កដោយទំនប់តាមដងទន្លេដែលជះឥទ្ធិពលលើការបំលាស់ទីរបស់ត្រី) សន្និដ្ឋានថា គឺគ្មានបច្ចេកទេសដែលមានស្រាប់ សម្រាប់សម្រួលដល់ការបំលាស់របស់ត្រី ហើយក៏គ្មានដំណោះស្រាយចំពោះផលប៉ះពាល់នៃការរាំងខ្ទប់នៃទំនប់តាមដងទន្លេប្រកបដោយប្រសិទ្ធភាពទេ [8]។

ក្រៅពីការទទួលស្គាល់ថា គ្មានវិធីសម្រួលដល់ការបំលាស់ទីរបស់ត្រីប្រកបដោយប្រសិទ្ធភាព (បើតាមអ្នកចូលរួមម្នាក់នៅកិច្ចប្រឹក្សាយោលបល់កម្មវិធីវារីអគ្គីសនីរបស់ MRC) ការបន្តកិច្ចពិភាក្សាគឺផ្តោតជាសំខាន់លើការដូរដេញ និងការបន្ធូរបន្ថយផលប៉ះពាល់ [25]។ ជាពិសេស បទពិសោធន៍ទន្លេកូឡំប៊ី ត្រូវបានលើកយកមកនិយាយថា ជាប្រតិបត្តិគំរូដែលអាចបន្ធូរបន្ថយផលប៉ះពាល់មួយប្រកបដោយជោគជ័យ នេះមិនបាននិយាយទៅពីការអនុវត្តក្នុងបរិបទនៅទន្លេមេគង្គទេ។ "ទន្លេកូឡំប៊ីជាកន្លែងដែលមានប្រភេទត្រីដូចត្រីសូម៉ុងពី៥ទៅ៨

ប្រភេទ ខុសពីចំនួនប្រភេទត្រីដែលមាននៅទន្លេមេគង្គគឺប្រហែលជា១.៣០០ប្រភេទ [25:4]។

"គ្មានចំណុចដែលច្បាស់លាស់ថាតើកត្តាអ្វី និងការវាយតម្លៃបែបណាអាចយកមកប្រើក្នុងការពិចារណាលើ "ការដូរដេញ" រវាងមច្ឆជាតិទន្លេមេគង្គ និងទំនប់លើដងទន្លេនោះទេ ឬថាតើអ្វី និងរបៀបអ្វីដែលនឹងយកមកប្រើដើម្បីធានាថា ផលបះពាល់លើសង្គមនឹងត្រូវបានចាត់ចែងចូលក្នុងការវាយតម្លៃលើថ្លៃចំណាយ និងចំណូលនៃទំនប់តាមដងទន្លេដែលបានស្នើសុំ។

អ្វីដែលច្បាស់លាស់បានពីការស្រាវជ្រាវរហូតដល់បច្ចុប្បន្នគឺថា ត្រីជាធនធានដ៏សំខាន់របស់ប្រជាជនរស់នៅតាមអាងទន្លេមេគង្គ។ ដូចឯកសារបច្ចេកទេសរបស់MRC ឆ្នាំ២០០២ មួយបានកត់សម្គាល់ថា "ថ្លៃចំណាយដែលនឹងមកជំនួសនូវធនធានពីធម្មជាតិនេះ ជាមួយនឹងប្រភពនៃអាហារ ប្រាក់ចំណូល និងការងារគឺពិតជាច្រើន មិនអាចកាត់ថ្លៃបានទេ។ តាមទសន្សវិស័យនេះ គឺមានភាពច្បាស់លាស់ណាស់ថា ការអភិរក្សមច្ឆជាតិជាបញ្ហាស្លាប់រស់សម្រាប់សុវត្ថិភាពស្បៀង និងស្ថេរភាពសង្គម [16:53]។

## ឯកសារយោង ៖


1. Mekong Secretariat (1994) *Mekong Mainstream Run-of-River Hydropower: Main Report*. A study conducted by Compagnie National du Rhone, Lyon, France in cooperation with Acres International Ltd and Mekong Secretariat Study Team. Mekong Secretariat, Bangkok, Thailand.
2. Hill, Mark T. and Susan A. Hill, Don Chapman Consultants (1994) *Fisheries Ecology and Hydropower in the Mekong River: An Evaluation of Run-of-the-River Projects*. Mekong Secretariat, Bangkok, Thailand.
3. Interim Mekong Committee (1992) *Fisheries in the Lower Mekong Basin (Review of the Fishery Sector in the Lower Mekong Basin): Main Report*, Interim Committee for Coordination of Investigations of the Lower Mekong Basin, Bangkok, Thailand.
4. Jeremy Bird, MRCS CEO, Remarks to Informal Donor Meeting: Vision for the Next Three Years, 20 June 2008. http://www.mrcmekong.org/MRC_news/speeches/ceo-speech-IDM-20Jun08.htm
5. Baran, E., Jantunen T., and Chong C.K. (2007) *Values of inland fisheries in the Mekong River Basin*. WorldFish Center, Phnom Penh, Cambodia.
6. Coates D., Ouch Poeu, Ubolratana Suntornratana, N Thanh Tung & Sinthavong Viravong (2003) *Biodiversity and fisheries in the Lower Mekong Basin*. Mekong Development Series No. 2. Mekong River Commission (MRC), Phnom Penh, Cambodia.
7. Baran E and B. Ratner (2007) *The Don Sahong Dam and Mekong Fisheries*. A science brief from the WorldFish Center, Phnom Penh, Cambodia.
8. Dugan, P. Facilitator of Fishery Expert Group Meeting at MRC (2008) "Examining the barrier effects of mainstream dams to fish migration in the Mekong, with an integrated perspective to the design of mitigation measures (Conclusions from an independent Expert Group Meeting)", presented at *Regional Multi-Stakeholder Consultation of the MRC Hydropower Programme*, 25-27 September 2008 in Vientiane, Lao PDR. http://www.mrcmekong.org/download/programmes/hydropower/presentations/Consultation%20Presentation%20(final%2025%20Sep%2008).pdf
9. MRC (2008) Fisheries Programme http://www.mrcmekong.org/programmes/fisheries.htm
10. MRC (2005) *MRC Programme for Fisheries Management and Development Cooperation Annual Report 2004/2005*. Mekong River Commission, Vientiane, Lao PDR.
11. MRC (2004) *MRC Programme for Fisheries Management and Development Cooperation Annual Report 2003/2004*. Mekong River Commission, Vientiane, Lao PDR.
12. Hortle, K.G. (2007) *Consumption and the yield of fish and other aquatic animals from the Lower Mekong Basin*. MRC Technical Paper No. 16. Mekong River Commission, Vientiane, Lao PDR.
13. MRC (2003) *State of the Basin Report: 2003*. Mekong River Commission, Phnom Penh, Cambodia.
14. BARAN Eric (2006) *Fish migration triggers in the Lower Mekong Basin and other tropical freshwater systems*. MRC Technical Paper No. 14. Mekong River Commission, Vientiane, Lao PDR.
15. Poulsen, Anders, Ouch Poeu, Sintavong Viravong, Ubolratana Suntornratana & Nguyen Thanh Tung (2002) *Deep pools as dry season fish habitats in the Mekong Basin*. MRC Technical Paper No. 4. Mekong River Commission, Phnom Penh, Cambodia.
16. Sverdrup-Jensen, S. (2002) *Fisheries in the Lower Mekong Basin: Status and Perspectives*. MRC Technical Paper No. 6. Mekong River Commission, Phnom Penh, Cambodia.
17. Poulsen A.F., Ouch Poeu, Sintavong Viravong, Ubolratana Suntornratana and Nguyen Thanh Tung (2002) *Fish migrations of the Lower Mekong River Basin: implications for development, planning and environmental management*. MRC Technical Paper No. 8. Mekong River Commission, Phnom Penh, Cambodia.
18. Hortle, K.G., S. Lieng and J. Valbo-Jorgensen (2004) *An introduction to Cambodia's inland fisheries*. Mekong Development Series No. 4. Mekong River Commission, Phnom Penh, Cambodia.
19. Baran E., P. Starr, and Y. Kura (2007) *Influence of built structures on Tonle Sap fisheries: Synthesis Report*. Cambodia National Mekong Committee and the WorldFish Center. Phnom Penh, Cambodia.

20. Poulsen, A.F., K.G. Hortle, J. Valbo-Jorgensen, S. Chan, C.K. Chhuon, S. Viravong, K. Bouakhamvongsa, U. Suntornratana, N. Yoorong, T.T. Nguyen and B.Q. Tran (2004) *Distribution and Ecology of Some Important Riverine Fish Species of the Mekong River Basin*. MRC Technical Paper No. 10. Mekong River Commission, Phnom Penh, Cambodia.
21. Barlow, C. (2008) "Inland Fisheries in the Lower Mekong Basin – Importance, Challenges and mechanisms to Meet those Challenges." Paper presented at the *International Symposium: Sustaining fish diversity, fisheries and aquaculture in the Mekong Basin*, Ubon Ratchathani University, Thailand, 3-5 September 2008, pp. 18-19.
22. Chan, S., S. Putrea, K. Sean and K.G. Hortle (2003) "Using local knowledge to inventory deep pools, important fish habitats in Cambodia." In: *Proceedings of the 6th Technical Symposium on Mekong Fisheries*, Lao PDR 26-28 November, pp. 57-76.
23. World Bank & Asian Development Bank (2006) *WB/ADB Joint Working Paper on Future Directions For Water Resources Management In The Mekong River Basin: Mekong Water Resources Assistance Strategy (MWRAS)*, June (Draft).
24. Podger G., Beecham R., Blackmore D., Perry C., Stein R. (2004) *Modelled observations on development scenarios in the Lower Mekong Basin*. Report of the Mekong Regional Water Resources Assistance Strategy. World Bank, Vientiane, Lao PDR.
25. Friend, R. (2008) "Reflections on MRC Hydropower Programme Consultation." *M-Power Research Update* 26:4. http://www.mpowernet.org/download_pubdoc.php?doc=4327

## លំដាប់ព្រឹតិបត្រទន្លេមេគង្គរបស់ AMRC

ព្រឹតិបត្រនេះ គឺមានលេខរៀងទី៩ក្នុងចំណោមលំដាប់ប័ណ្ណព័ត៌មានដែលត្រូវបានបោះពុម្ភដោយមជ្ឈមណ្ឌលធនធានទន្លេមេគង្គអូស្ត្រាលី (AMRC) សាកលវិទ្យាល័យស៊ីដនី ដែលប្រើសម្រាប់និស្សិត សាស្ត្រាចារ្យ និងអ្នកផ្សេងទៀតដែលចាប់អារម្មណ៍ក្នុងតំបន់ទន្លេមេគង្គ។

AMRC ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ដើម្បីពង្រីកការស្រាវជ្រាវ ពិភាក្សា និងជជែកដេញដោលលើបញ្ហាអភិវឌ្ឍន៍ និងបរិស្ថានក្នុងតំបន់ទន្លេមេគង្គ។ AMRC ជាកន្លែងទំនាក់ទំនងសម្រាប់ព័ត៌មាន កិច្ចពិភាក្សា និងបង្កើតសកម្មភាពក្នុងការគ្រប់គ្រងដំណើរការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាព និងសមភាពសម្រាប់តំបន់ទន្លេមេគង្គ។

ប្រសិនបើលោកអ្នកចង់ធ្វើវិចារណ៍លើការបោះពុម្ភផ្សាយនេះ ឬក៏ចង់ចូលរួមក្នុងបញ្ជីទទួលព្រឹត្តិបត្រសង្ខេបនេះទៅថ្ងៃអនាគត សូមទំនាក់ទំនងមក ៖

Australian Mekong Resource Centre
C/- School of Geosciences (F09)
University of Sydney
NSW 2006 Australia
Tel: +61-2-9351-7796
Fax: +61-2-9351-8627
mekong@mail.usyd.edu.au
http://www.mekong.es.usyd.edu.au/

ព្រឹត្តិបត្រសង្ខេបនេះ រៀបចំឡើងដោយ Gary Lee និង Natalia Scurrah ដោយមានការឧបត្ថម្ភពីអង្គការ Oxfam អូស្ត្រាលី និងគណនេយ្យអនុស្សាវរីយ៍របស់ Charlie Pahlman ។